ហត្ថា
Hattha Bank

Subsidiary of krungsri bank
A member of MUFG, a global financial group

# របាយការណ៍ត្រីមាសទី៤

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី៤ ឆ្នាំ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | ៦ ៣៦៩ ៨៧០ | ៤ ៩៩៩ ៣២៣ | ៣ ៧១៦ ៩៦៦ |
| បំណុលសរុប (លានរៀល) | ៥ ៣១៩ ៦៤៥ | ៤ ១៩១ ០០៦ | ៣ ០៤៨ ៩៩៦ |
| មូលធនសរុប (លានរៀល) | ១ ០៥០ ២២៥ | ៨០៨ ៣១៧ | ៦៦៧ ៩៧០ |
| លទ្ធផលហិរញ្ញវត្ថុ | ត្រីមាសទី៤ ឆ្នាំ២០២០ | ត្រីមាសទី៤ ឆ្នាំ២០១៩ | ត្រីមាសទី៤ ឆ្នាំ២០១៨ |
| ចំណូលសរុប (លានរៀល) | ២០០ ៥៧៧ | ១៦៥ ១១៤ | ១២៦ ២២៥ |
| ចំណេញ/(ខាត)មុនបង់ពន្ធ (លានរៀល) | ៤៤ ៣៣១ | ៤០ ៣៤៤ | ២៧ ២៦០ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ (លានរៀល) | ៣៧ ៨៥៩ | ៤៨ ១១៧ | ២១ ៧១៥ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (លានរៀល) | ៣៦ ២៨១ | ៤៦ ៥៨២ | ១៦ ២២១ |
| អនុបាតហិរញ្ញវត្ថុ | ត្រីមាសទី៤ ឆ្នាំ២០២០ | ២០១៩ | ២០១៨ |
| អនុបាតសាធនភាព (ភាគរយ) | ១៧,៨ | ១៩,៤ | ២០,០ |
| អនុបាតបំណុលធៀបនឹងមូលធន (ភាគរយ) | ៥០៧ | ៥១៨ | ៤៥៦ |
| អនុបាតសន្ទនីយភាព (ភាគរយ) | ១៣១,០ | ១១៣,៩ | ១៧៧,០ |
| អនុបាតឥណទានមិនដំណើរការ[1] (ភាគរយ) | ១,៣១ | ០,៣០ | ០,៦៧ |
| អនុបាតបញ្ញើឥណទាន (ភាគរយ) | ៥៩,៩ | ៥៧,០ | ៦៣,៤ |
| | ត្រីមាសទី៤ ឆ្នាំ២០២០ | ត្រីមាសទី៤ ឆ្នាំ២០១៩ | ត្រីមាសទី៤ ឆ្នាំ២០១៨ |
| អនុបាតចំណេញភាពធៀបនឹងទ្រព្យសកម្ម(ភាគរយ) | ០,៥៩ | ០,៩៦ | ០,៤៤ |
| អនុបាតចំណេញភាពធៀបនឹងមូលធន (ភាគរយ) | ៣,៦០ | ៥,៩៥ | ២,៤៣ |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ភាគរយ) | ១៥៤ | ១៦៣ | ១៥២ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

[1] និយមន័យរបស់ធនាគារជាតិនៃកម្ពុជា


ស្ថានភាពហិរញ្ញវត្ថុ(គិតជាលានរៀល)
៦ ៣៦៩ ៨៧០
៤ ៩៩៩ ៣២៣
៣ ៧១៦ ៩៦៦
៥ ៣១៩ ៦៤៥
៤ ១៩១ ០០៦
៣ ០៤៨ ៩៩៦
១ ០៥០ ២២៥
៨០៨ ៣១៧
៦៦៧ ៩៧០
ទ្រព្យសកម្ម
បំណុលសរុប
មូលធនសរុប
ត្រីមាសទី៤ ឆ្នាំ -២០២០
២០១៩
២០១៨


លទ្ធផលហិរញ្ញវត្ថុ(គិតជាលានរៀល)
២០០ ៥៧៧
១៦៥ ១១៤
១២៦ ២២៥
៤៤ ៣៣១
៤០ ៣៤៤
២៧ ២៦០
៣៧ ៨៥៩
៤៨ ១១៧
២១ ៧១៥
ចំណូល…
ចំណេញ…
ចំណេញ…
ត្រីមាសទី៤ ឆ្នាំ -២០២០
ត្រីមាសទី៤ ឆ្នាំ -២០១៩
ត្រីមាសទី៤ ឆ្នាំ -២០១៨

# សមាសភាពក្រុមប្រឹក្សាភិបាល



លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល



លោកឧកញ៉ា ហួត អៀងតុង
អភិបាល



កញ្ញា Duangdao WONGPANITKRIT
អភិបាល



អ្នកស្រី Voranuch DEJAKAISAYA
អភិបាល



លោក Chandrashekar S.K.
អភិបាល



លោក Wanchairabin JITWATTANATAM
អភិបាល



លោក ឡូញ ហៃ
អភិបាលឯករាជ្យ



លោក ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ



លោក ប៉ាក សេរីវឌ្ឍនា
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ឆ្នាំ២០២០ គឺជាឆ្នាំមួយមានភាពច្របូកច្របល់ខ្លាំងបំផុត តែទោះជាយ៉ាងណាក៏ដោយ ធនាគារ ហត្ថា ម.ក បានសម្រេចនូវលទ្ធផលចុងឆ្នាំគួរជាទីពេញចិត្ត ដោយបានជួយគាំទ្រដល់អតិថិជន និងសម្រេចបាននូវលទ្ធផលផែនការអាជីវកម្មរបស់ខ្លួន។

នៅត្រីមាសចុងក្រោយនៃឆ្នាំ ២០២០ សេដ្ឋកិច្ចកម្ពុជា បានបន្តងើបឡើងវិញ ទោះបីស្ថានភាពជំងឺកូវីដ១៩ នៅលើពិភពលោក នៅតែបន្តអូសបន្លាយ និងប៉ះពាល់ដល់ប្រទេសទាំងអស់ក៏ដោយ។ ជាមួយនោះ អាជីវកម្មក្នុងស្រុក និងការប្រើប្រាស់ក្នុងស្រុក ដែលជាក្បាលម៉ាស៊ីនដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចកម្ពុជា ក៏ត្រូវរងផលប៉ះពាល់យ៉ាងខ្លាំងផងដែរ។ ខ្ញុំសូមកោតសរសើរចំពោះវិធានការយ៉ាងសកម្មរបស់រាជរដ្ឋាភិបាល និងធនាគារជាតិ នៃកម្ពុជា ក្នុងការជួយដោះស្រាយតម្រូវការរបស់អ្នកប្រកបអាជីវកម្ម និងស្ថាប័នហិរញ្ញវត្ថុ ដែលកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ បានធ្វើឱ្យសកម្មភាពអាជីវកម្មអាចនៅតែបន្តទៅមុខបាន ទោះបីមានបញ្ហាប្រឈមពីជំងឺរាតត្បាតក៏ដោយ។ រីឯធនាគារ ហត្ថា ម.ក មានកាតព្វកិច្ចក្នុងការពង្រីកការគាំទ្រ និងពេញចិត្តពីអតិថិជនបន្ថែមទៀត ទៅតាមអ្វីដែលអាចធ្វើទៅបាន ស្របតាមការណែនាំពីធនាគារជាតិ នៃកម្ពុជា ចំពោះការលើកទឹកចិត្តដល់ប្រព័ន្ធធនាគារ ក្នុងការជួយអនុគ្រោះដល់អតិថិជន ដែលបានទទួលផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលពីជំងឺកូវីដ១៩។ នៅក្នុងឆ្នាំ២០២០ ធនាគារ ហត្ថា ម.ក បានជួយសម្រាលបន្ទុកដល់អតិថិជនរបស់ខ្លួន តាមរយៈកម្មវិធីការរៀបចំឥណទានសារឡើងវិញ ជូនដល់អតិថិជនជាង ១៣ ០០០ នាក់ ស្មើនឹងចំនួនទឹកប្រាក់ជិត $ ១៤០ លានដុល្លារអាមេរិក ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ យើងនឹងនៅតែឈររួមគ្នាជាមួយអតិថិជនរបស់យើង និងបន្តគាំទ្រពួកគាត់ ដើម្បីឆ្លងកាត់ពេលវេលាដ៏លំបាកនេះ ឆ្ពោះទៅឆ្នាំ ២០២១ ។

ក្នុងអំឡុងពេលនៃការផ្ទុះឆ្លងសហគមន៍នៅក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២០ ធនាគារ ហត្ថា ម.ក បានចេញវិធានការការពារដើម្បីធានាសុខភាព និងសុវត្ថិភាពសម្រាប់អតិថិជន និងបុគ្គលិករបស់ខ្លួន ជាក់ស្តែងដូចជាការដាក់បុគ្គលិកឲ្យស្ថិតនៅដាច់ដោយឡែក ចំពោះអ្នកបានប៉ះពាល់ទៅនឹងកន្លែងដែលមានករណីជំងឺកូវីដ១៩ឆ្លង ដោយបន្តបំពេញការងារពីគេហដ្ឋានរបស់ខ្លួនតាមវេន ដើម្បីរក្សាគម្លាតនៅក្នុងសង្គម។

ចំពោះដំណើរការអាជីវកម្មរបស់ធនាគារ ហត្ថា ម.ក សម្រាប់ត្រីមាសចុងក្រោយ ឃើញថាមានការកើនឡើងគួរឲ្យកត់សំគាល់លើសមតុល្យប្រាក់កម្ចី និងប្រាក់បញ្ញើសន្សំ ដែលជាការឆ្លុះបញ្ចាំងពីការងើបឡើងវិញនូវតម្រូវការ និងការទុកចិត្តពីទីផ្សារ។ យើងបានបង្កើនផលប័ត្រឥណទានរហូតដល់ ១ ៣២៣ លានដុល្លារអាមេរិកដែលបានកើនឡើង ១៦ ភាគរយ បើប្រៀបធៀបទៅនឹងត្រីមាសមុន ប្រាក់បញ្ញើសន្សំរបស់យើង បានឡើងដល់កំណត់ត្រាថ្មីចំនួន ៧៩៣ លានដុល្លារអាមេរិក ដែលបានកើនឡើង ១៧ ភាគរយ បើធៀបនឹងត្រីមាសដូចគ្នា ចំណែកឥណទានមិនដំណើរការ គឺបានដោះស្រាយកាត់បន្ថយយ៉ាងច្រើនពី ១,៤៤% មកត្រឹម ០,៧០% ខណៈពេលដែលយើង បានបន្តអនុវត្តពង្រឹងការគ្រប់គ្រងគុណភាពទ្រព្យសកម្ម និងអតិថិជន ក្នុងការកែលម្អជំហរ ហិរញ្ញវត្ថុរបស់ពួកគាត់ ហើយអនុបាតសាធនភាពរបស់យើង ស្ថិតនៅក្នុងកម្រិតចំនួន ១៧,៨% ដែលវាខ្ពស់ជាងការកំណត់របស់ធនាគារជាតិនៃកម្ពុជា។ ធនាគារ ហត្ថា ម.ក បានដាក់ឲ្យដំណើរការធនាគារចល័តទំនើបថ្មីដោយជោគជ័យជាមួយអតិថិជនប្រើប្រាស់ធនាគារចល័តថ្មីរបស់យើងមានចំនួន ១៦ ០០០ នាក់ ដែលនេះវាជាកម្លាំង ចលករដ៏សំខាន់ក្នុងការជួយបន្តបង្កើនអតិថិជនប្រើប្រាស់ធនាគារចល័តរបស់យើងទៅមុខទៀត ស្របតាមយុទ្ធ-សាស្ត្រក្នុងការពង្រីកអាជីវកម្មឌីជីថល។

យើងរំពឹងថានឹងក្លាយជាធនាគារពាណិជ្ជឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជា ដែលផ្តល់នូវផលិតផលនិងសេវាកម្មយ៉ាងទូលំទូលាយដល់អតិថិជនរបស់យើង សម្រាប់ជួយឧបត្ថម្ភគាំទ្រដល់សេដ្ឋកិច្ចកម្ពុជា យោងតាមផែនការអាជីវកម្មរយៈពេលមធ្យមពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ របស់ខ្លួន ហើយដោយសារធនាគារ ហត្ថា ម.ក គឺជាបុត្រសម្ព័ន្ធរបស់ធនាគារក្រុងស្រី និងជាសមាជិករបស់សម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ MUFG យើងពិតជាមានទំនុកចិត្តថា យើងអាចប្រើប្រាស់ប្រយោជន៍អនុភាពបណ្តាញថ្នាក់តំបន់ និងលើពិភពលោករបស់ក្រុមហ៊ុនមេ ដើម្បីបន្តពង្រឹងជូនដល់អតិថិជនកម្ពុជារបស់ ធនាគារ ហត្ថា ម.ក។

ជាចុងក្រោយ ខ្ញុំសូមជូនពរឲ្យអ្នកទាំងអស់គ្នាមានសុខភាពរឹងមាំ និងសុវត្ថិភាពក្នុងការស៊ូទ្រាំរាល់ការលំបាក និងឧបសគ្គនានា ដែលមាននៅពេលខាងមុខ សូមឲ្យឆ្នាំ ២០២១ គឺជាឆ្នាំជោគជ័យ និងវិបុលភាពដ៏ធំធេងសម្រាប់វិនិយោគិន និងអតិថិជនរបស់យើង។

កាលបរិច្ឆេទ៖ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១

ហត្ថលេខា និង ត្រា




លោក Dan HARSONO

ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក

ជាការពិតណាស់ នៅក្នុងឆ្នាំ២០២០នេះ ជំងឺកូវីដ១៩ បានធ្វើឱ្យសេដ្ឋកិច្ចពិភពលោក ក៏ដូចជាកំណើនសេដ្ឋកិច្ចកម្ពុជា មានការធ្លាក់ចុះ ដែលបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការរស់នៅ និងអាជីវកម្មនានារបស់ប្រទេសកម្ពុជា។ ទោះជាយ៉ាងនេះក្តី ធនាគារ ហត្ថា ម.ក អាចឆ្លងផុតពេលវេលាដ៏លំបាកមួយនេះ ដោយសម្រេចបាន សមិទ្ធផលធំៗទៅតាមផែនការដូចជា៖ ការកម្លាយខ្លួនដោយជោគជ័យទៅជាធនាគារពាណិជ្ជ សមតុល្យប្រាក់កម្ចី ប្រាក់បញ្ញើសន្សំ និងប្រាក់ចំណេញលើសផែនការ គួរជាទីពេញចិត្ត រីឯឥណទានមិនដំណើរការស្ថិតនៅក្នុងកម្រិតហានិភ័យទាបល្អប្រសើរ។ សមិទ្ធផល ដែលយើងទទួលបានទាំងអស់នេះ គឺសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា ធនាគារ ហត្ថា ម.ក នៅតែរក្សាជំហរយ៉ាងរឹងមាំ និងឈានមុខគេនៅលើទីផ្សារហិរញ្ញវត្ថុកម្ពុជា។ យ៉ាងណាមិញ សូមអតិថិជន មេត្តាជ្រាបថា ធនាគារ ហត្ថា ម.ក មានផលិតផល/សេវាកម្មដូចជា ធនាគារហត្ថាចល័ត អេធីអឹម សន្សំផលច្រើន (HYSA) សេវាកម្មបែបធនាគារពាណិជ្ជ និងមានផលិតផល/សេវាកម្មទំនើបថ្មីៗ ដែលត្រូវដាក់បម្រើដល់អតិថននាពេលដ៏ឆាប់ខាងមុខ។

ទន្ទឹមនឹងនេះផងដែរ ដើម្បីចូលរួមទប់ស្កាត់ និងប្រឆាំងជំងឺកូវីដ១៩ នៅក្នុងប្រទេសកម្ពុជាយើង ធនាគារ ហត្ថា ម.ក បានបង្កើតគណនីសប្បុរសធម៌កូវីដ១៩ សម្រាប់ឱ្យអតិថិជន សប្បុរសជន និងបុគ្គលិកធនាគារ ហត្ថា ម.ក ទាំងអស់បរិច្ចាគថវិកា ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការទិញវ៉ាក់សាំងការពារជំងឺកូវីដ១៩ ជូនប្រជាជនកម្ពុជាដោយឥតគិតថ្លៃ។ នេះហើយ គឺជាសកម្មភាពមួយដ៏មានអត្ថន័យបំផុត សម្រាប់ប្រទេសជាតិយើងទាំងមូល។ បន្ថែមពីលើនេះ ធនាគារ ហត្ថា ម.ក បានចូលរួមបរិច្ចាគថវិកាជាប្រាក់រៀលចំនួន ២០០ ០០០ ០០០៛ (ពីររយលានរៀល) ផងដែរ ដើម្បីចូលរួមជាមួយរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាតត្បាតជំងឺកូវីដ១៩។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ ហត្ថា ម.ក បានទទួលលទ្ធផលល្អប្រសើរដូចខាងក្រោម៖

-សមតុល្យប្រាក់កម្ចីលើសផែនការតែចំនួន ១១៥ លានដុល្លារអាមេរិក

-ប្រាក់បញ្ញើសន្សំលើសផែនការប្រមាណជិត ១៧២ លានដុល្លារអាមេរិក

-ប្រាក់ចំណេញលើសផែនការប្រមាណជិត ១២ លានដុល្លារអាមេរិក

-ឥណទានមិនដំណើរការគឺ ០,៧០% ទាបជាងផែនការចំនួន ១,៤២%

ជាចុងក្រោយ សូមគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់បន្តខិតខំប្រឹងប្រែងធ្វើការងារតាមជំនាញរៀងៗខ្លួន និងពង្រីកពង្រឹងចំណេះជំនាញធនាគារបន្ថែម ដើម្បីបន្តដំណើរការរបស់យើងទៅមុខទៀត ដូចពាក្យស្លោករបស់យើង «រួមគ្នាសាងអនាគតដ៏ប្រសើរ» ។ យើងទាំងអស់គ្នា នឹងបន្តពួតដៃគ្នាកសាងកេរ្តិ៍ឈ្មោះ ធនាគារ ហត្ថា ម.ក ឱ្យកាន់តែល្បីរន្ទឺទាំងក្នុងប្រទេសកម្ពុជា និងលើឆាកអន្តរជាតិ។

កាលបរិច្ឆេទ៖ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១

ហត្ថលេខា

លោកឧកញ៉ា ហួត អៀងតុង

ប្រធានអគ្គនាយក

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

សមាសភាពក្រុមប្រឹក្សាភិបាល ........ iii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល........ iv

សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក........ v

ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ ........ ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ខ- លក្ខណៈនៃធុរកិច្ច ........ ១

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ២

ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច........ ២

ខ- រចនាសម្ព័ន្ធចំណូល ........ ៣

ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ........ ៤

ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង........ ៥

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ........ ៥

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ៥

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល........ ៥

ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ........ ៥

ង- ផលប៉ះពាល់នៃអតិផរណា........ ៦

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ៦

## ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ

### ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ធនាគារ ហត្ថា ម.ក |
| ឈ្មោះជាអក្សរឡាតាំង | Hattha Bank Plc. |
| កូដស្តង់ដារ | KH20000718B4 |
| អាសយដ្ឋាន | អគារលេខ ៦០៦ ផ្លូវ២៧១ ភូមិសន្សំកុសល ៣ សង្កាត់បឹងទំពន់ ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | ០២៣ ៩៩៤ ៣០៤ |
| គេហទំព័រ | www.hatthabank.com |
| អ៊ីម៉ែល | info@hatthabank.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៥៣៥៥ (ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១) |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ធ-៥៦ ចេញដោយ: ធនាគារជាតិនៃកម្ពុជាកាលបរិច្ឆេទ: ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ ១៦៥/១៨គ.ម.ក. កាលបរិច្ឆេទ: ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| តំណាងធនាគារ ហត្ថា ម.ក ដោយ | លោកឧកញ៉ា ហួត អៀងតុង |

### ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ ហត្ថា ម.ក គឺជាធនាគារមួយក្នុងចំណោមធនាគារឈានមុខផ្សេងទៀតនៅកម្ពុជា ដែលទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារពាណិជ្ជពី ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២០។ ជាមួយបទពិសោធន៍ក្នុងការបម្រើសេវាហិរញ្ញវត្ថុទៅកាន់ប្រជាជនកម្ពុជាអស់រយៈពេលជាង ២៦ឆ្នាំ ក្រោយការផ្លាស់ប្តូរមុខមាត់ថ្មីរបស់ខ្លួន ធនាគារ ហត្ថា បានកែលម្អ និងដាក់ឱ្យប្រើប្រាស់បន្ថែមនូវសេវាកម្មហិរញ្ញវត្ថុជាច្រើនផ្សេងទៀតក្នុងនោះមានដូចជា៖ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាធនាគារចល័ត (Hattha Mobile) ដាក់ឱ្យប្រើប្រាស់នូវសេវាផ្ទេរប្រាក់ឆ្លងធនាគារ សេវាឥណទានវិបារូបន៍ សេវាបញ្ញើសន្សំផលច្រើន (HYSA Flexi and HYSA Corporate) និងការត្រៀមខ្លួនក្នុងការផ្តល់ជូនសេវាធនាគារថ្មីៗផ្សេងទៀត បន្ថែមលើសេវាដែលមានស្រាប់ដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាបើកប្រាក់បៀវត្ស និងជាអ្នកណែនាំលក់សេវាធានារ៉ាប់រងផងដែរ។

គិតត្រឹម ខែ ធ្នូ ឆ្នាំ ២០២០ សមតុល្យប្រាក់បញ្ញើសន្សំ របស់ ធនាគារ ហត្ថា មានចំនួនជាង ៧៩៣ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជនប្រាក់បញ្ញើសន្សំ ២៧១ ៥៩៨ នាក់ និងផលប័ត្រឥណទានសរុបមាន ចំនួនប្រមាណ

១ ៣២៣ លានដុល្លារអាមេរិក ដែលបម្រើអតិថិជន ចំនួន ១៨៤ ៤៩០ នាក់ តាមរយៈសាខាចំនួន ១៧៧ និងម៉ាស៊ីនអេធីអឹមចំនួន ១៣៧ទីតាំង នៅទូទាំងប្រទេស។

ធនាគារ ហត្ថា គឺជាបុត្រសម្ព័ន្ធរបស់ ធនាគារ ក្រុងស្រ៊ី។ ធនាគារ ក្រុងស្រ៊ី (ធនាគារ អាយុធ្យា ម.ក និង ក្រុមហ៊ុនជាបុត្រសម្ព័ន្ធ) គឺជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេលំដាប់ទី៥ នៅក្នុងព្រះរាជាណាចក្រថៃ ដោយយោងលើទំហំទ្រព្យសកម្ម ផលប័ត្រឥណទាន និងប្រាក់បញ្ញើសន្សំ និងជាធនាគារមួយក្នុងចំណោមធនាគារ D-SIBs ចំនួនប្រាំ ដែលបានធ្វើប្រតិបត្តិការអាជីវកម្មជូនអតិថិជនរបស់ខ្លួនអស់រយៈពេល ៧៥ ឆ្នាំ មកហើយនៅក្នុងព្រះរាជាណាចក្រថៃ។ ធនាគារក្រុងស្រ៊ី គឺជាសមាជិកយុទ្ធសាស្ត្ររបស់សម្ព័ន្ធហិរញ្ញវត្ថុ MUFG ដែលជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេបង្អស់នៅជប៉ុន ក៏ដូចជាសម្ព័ន្ធហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមសម្ព័ន្ធហិរញ្ញវត្ថុធំៗផ្សេងទៀតនៅលើពិភពលោក។

### គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ដូចដែលយើងទាំងអស់គ្នាបានដឹងរួចមកហើយថា ការរីករាតត្បាតនៃជម្ងឺកូវីដ១៩ បានបង្កឱ្យមានផលលំបាកយ៉ាងខ្លាំងដល់សកម្មភាពអាជីវកម្មសំខាន់ៗជាច្រើនទាំងនៅក្នុងប្រទេសកម្ពុជាក៏ដូចជាពិភពលោកទាំងមូល។ ទោះជាយ៉ាងនេះក្តី ធនាគារ ហត្ថា នៅតែបន្តប្រតិបត្តិការរបស់ខ្លួនយ៉ាងរឹងមាំ និងប្រកបដោយទំនុកចិត្តពីអតិថិជន សាធារណជន និងគ្រប់ភាគីពាក់ព័ន្ធ។ ស្របតាមគោលដៅអាជីវកម្មយូរអង្វែងរបស់ខ្លួន នៅក្នុងត្រីមាសទី៤ ឆ្នាំ ២០២០ ធនាគារ ហត្ថា បានអនុវត្តក៏ដូចជាសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនដូចជា ធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធរបស់ស្ថាប័នសម្រាប់ឆ្នាំថ្មី ២០២១ ចុះកិច្ចព្រមព្រៀងជាមួយដៃគូអាជីវកម្មក្នុងការផ្តល់ជូនតម្លៃពិសេសសម្រាប់អតិថិជន ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការបរិច្ចាគទឹកប្រាក់ទិញវ៉ាក់សាំងការពារជំងឺកូវីដ១៩ រៀបចំនិងបណ្តុះបុគ្គលិកគ្រប់ជាន់ថ្នាក់ទូទាំងប្រទេសអំពីការប្រើប្រាស់ស្លាកសញ្ញារបស់ធនាគារឱ្យបានត្រឹមត្រូវ ចូលរួមក្នុងសកម្មភាពសង្គមជាច្រើនផ្សេងទៀតដូចជា ការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងផ្នែកហិរញ្ញវត្ថុ សុខភាពនិងសុវត្ថិភាព និងការការពារបរិស្ថាន ដើម្បីធានាបាននូវនូវការផ្លាស់ប្រែវិជ្ជមានទៅកាន់អតិថិជន និងសង្គមជាតិរបស់ខ្លួន។

ស្របតាមស្មារតីរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងផ្តល់ឥណទានដែលមានការប្រាក់ទាបដើម្បីជំរុញដល់វឌ្ឍនភាពរបស់សហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា ធនាគារ ហត្ថា ផ្តល់ជូននូវអត្រាការប្រាក់យ៉ាងពិសេសត្រឹមតែ ៧% ក្នុងមួយឆ្នាំ ដើម្បីទ្រទ្រង់ សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាដែលជាផ្នែកមួយនៃការចូលរួមក្នុងគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម (SME Co-Financing Scheme) ក៏ដូចជាដើម្បីបង្កើនសន្ទុះនៃការរីកចម្រើនដល់សេដ្ឋកិច្ចជាតិ។ ទាំងនេះគឺជាសក្ខីភាពយ៉ាងប្រត្យក្សដែលថា ធនាគារ ហត្ថា គឺជាធនាគារមួយមានសមត្ថភាពពេញលេញ និងចក្ខុវិស័យច្បាស់លាស់ក្នុងការរក្សាបាននូវស្ថិរភាពអាជីវកម្មនៅលើទីផ្សារ ក៏ដូចជារួមចំណែកក្នុងការផ្តល់ជូនភាពរីកចម្រើនទៅកាន់អតិថិជន និងសង្គមជាតិរបស់ខ្លួន។

## ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| លទ្ធផលសម្រេចបានសំខាន់ៗ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| ផ្នែកសេវាឥណទាន | | |
| ចំនួនគណនីសេវាឥណទាន | ១៧៦ ៤៥៣ | ១៨៤ ៤៩០ |
| ឥណទាននៅក្នុងដៃអតិថិជន (ពាន់ដុល្លារអាមេរិក) | ១ ២០៧ ៣៥៩ | ១ ៣២២ ៧២៩ |
| ផ្នែកសេវាប្រាក់បញ្ញើសន្សំ | | |
| ចំនួនគណនីសេវាប្រាក់បញ្ញើសន្សំ | ២៦៥ ៩១៧ | ២៧១ ៥៩៨ |
| សមតុលប្រាក់បញ្ញើសន្សំ (ពាន់ដុល្លារអាមេរិក) | ៦២០ ៥២៣ | ៧៩២ ៦៤៧ |
| ផ្នែកសេវាកម្មផ្សេងៗទៀត | | |
| ចំនួនអ្នកប្រើប្រាស់កាតអេធីអឹម | ៥៣ ៩៥០ | ៥៤ ៩០៨ |
| ចំនួនអ្នកប្រើប្រាស់សេវាធនាគារចល័ត | ៩ ២០៤ | ១៦ ២៥៤ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច (ដុល្លារអាមេរិក) | ២០១ ៨៤៦ | ២៩៤ ៥១២ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតឥណទាន (ដុល្លារអាមេរិក) | ៣ ៣៩២ ៧១០ | ៧ ៧៣០ ៥៦៧ |
| ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត | | |
| ចំនួនការិយាល័យ | ១៧៧ | ១៧៧ |
| ចំនួនអេធីអឹម | ១៤៧ | ១៣៧ |
| ចំនួនបុគ្គលិក | ៥ ៤០៩ | ៥ ១៧៦ |

### ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៤ ឆ្នាំ ២០២០ | | ត្រីមាសទី៤ ឆ្នាំ ២០១៩ | | ត្រីមាសទី៤ ឆ្នាំ ២០១៨ | |
|---|---|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ១៩២ ០៧៣ | ៩៥,៨ | ១៦០ ៥៥៥ | ៩៧,២ | ១២១ ៤៧៦ | ៩៦,២ |
| ២ | ចំណូលផ្សេងៗ | ៨ ៥០៤ | ៤,២ | ៤ ៥៥៩ | ២,៨ | ៤ ៧៤៩ | ៣,៨ |
| ចំណូលសរុប | | ២០០ ៥៧៧ | | ១៦៥ ១១៤ | | ១២៦ ២២៥ | |

## ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

## ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ពីគណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ហើយដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

របាយការណ៍ហិរញ្ញវត្ថុទាំងនេះរបស់ធនាគារហត្ថាត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗ ដែលបាន ជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ធនាគារ ហត្ថា តែប៉ុណ្ណោះ ។

**ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ**

**ការវិភាគចំណូល**

ធនាគារ ហត្ថា មានចំណូល ២ប្រភេទធំៗគឺ ចំណូលពីការប្រាក់ និងចំណូលផ្សេងៗ

| | |
|---|---|
| **ចំណូលពីការប្រាក់រួមមាន៖** ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់ អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តា ធនាគារនានា។ ហើយចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។ | **ចំណូលផ្សេងៗរួមមាន៖** កម្រៃណែនាំសេវាធានារ៉ាប់រង កម្រៃផ្ទេរ-ប្រាក់ ចំណូលកម្រៃផ្សេងៗ ចំណូលបានមកពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ ។ល។ |

ចំណូលការប្រាក់ ជាចំណូលដ៏ធំនិងសំខាន់សម្រាប់ ធនាគារ ហត្ថា ដែលមានរហូតដល់ ៩៥,៨% នៃចំណូលសរុប។

**ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ**

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០នេះ គណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា យល់ថា ផលប៉ះពាល់ជាអវិជ្ជនៃការរីករាលដាលកូវីដ១៩ បានចាប់ផ្តើមមានកំណើនឡើងវិញនៅក្នុងត្រីមាសនេះ ជាលទ្ធផលធ្វើឱ្យប្រាក់ចំណេញមានការថយចុះធៀបនឹងត្រីមាសមុន។លទ្ធផលនេះ មកពីការកើនឡើង នៃការចំណាយលើឱនភាពតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ។

**គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល**

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០នេះ គណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា យល់ថាការលក់ និងចំណូលមានការកើនឡើងនៅក្នុងដំណាក់កាលកូវីដ១៩នេះ។

**ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ**

ធនាគារ ហត្ថា បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការជា រូបិយវត្ថុប្រាក់រៀល និងរូបិយប័ណ្ណប្រាក់ថៃបាត ត្រូវបានប្តូរទៅជា រូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរទ្រព្យសកម្មនិងបំណុល រូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

**ង- ផលប៉ះពាល់នៃអតិផរណា**

ធនាគារ ហត្ថា មិនបានកែប្រែអត្រាការប្រាក់ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាព ប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២០ នេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានៅតែបន្តអនុវត្តវិធានការដែលមានស្រាប់សំខាន់ៗជាច្រើនដើម្បីធានាឱ្យបាននូវកំណើន និងស្ថិរភាពសេដ្ឋកិច្ចជាតិ ដូចជាការបន្តផ្តល់ហិរញ្ញប្បទានគាំទ្រនិយោជិតដែលត្រូវបានព្យួរការងារ (ក្នុងវិស័យកាត់ដេរ វាយនភណ្ឌ ស្បែកជើង និងទេសចរណ៍) និងគ្រួសារដែលមានប័ណ្ណក្រីក្រ ដើម្បីឆ្លើយតបទៅនឹងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការរីករាលដាលជំងឺកូវីដ១៩។

ក្រៅពីនេះ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធបាគង ដែលជាប្រព័ន្ធទូទាត់អាចធ្វើឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ធ្វើការជាមួយគ្នា ដោយផ្តោតលើសុវត្ថិភាព ប្រសិទ្ធភាព កាត់បន្ថយចំណាយថ្លៃប្រតិបត្តិការ និងបរិយាប័ន្នហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជា បានឱ្យដឹងបន្ថែមថា ដោយគិតចាប់ពីពេលដាក់ឱ្យដំណើរការសាកល្បងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២០ ដែលជាថ្ងៃដាក់ឱ្យដំណើរការផ្លូវការនេះ មានគ្រឹះស្ថានសមាជិកចូលរួមដាក់ឱ្យដំណើរការប្រព័ន្ធបាគងចំនួន ១៨គ្រឹះស្ថាន ក្នុងនោះមាន១៦ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ និង ២ ទៀតគឺជាគ្រឹះស្ថានផ្តល់សេវាទូទាត់។ ប្រព័ន្ធបាគងនឹងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដែលប្រព័ន្ធនេះត្រូវបានបង្កើតឡើងក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជា និងដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន។

បន្ថែមពីលើនេះ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជា បានចេញរបាយការណ៍ស្តីពី "វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យធនាគារឆ្នាំ២០២០ និងទស្សនវិស័យឆ្នាំ២០២១" ដែលក្នុងនោះ ធនាគារជាតិបានព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជានូវអត្រា ៤% ក្នុងឆ្នាំ២០២១ ដោយផ្តោតសំខាន់ថា ការបន្តពង្រឹងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកនឹងជួយគាំទ្រ និងកាត់បន្ថយផលប៉ះពាល់មកលើសេដ្ឋកិច្ចជាតិពីការថមថយនៃការនាំចេញ។ លើសពីនេះទៀត ការអនុវត្តគោលនយោបាយជាតិក្នុងការជំរុញការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម ការជំរុញនវានុវត្តន៍ភាព និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងគ្រប់វិស័យ នឹងមានសារៈសំខាន់ក្នុងជួយពង្រឹងការរីកចម្រើនក្នុងស្រុក។ ទាក់ទងនឹងវិស័យធនាគារវិញ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងការត្រួតពិនិត្យប្រព័ន្ធធនាគារ តាមរយៈយន្តការក្នុងការបន្តផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវខ្ពស់ លើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់សាធារណជន ពង្រឹងកិច្ចគាំពារអតិថិជន រក្សាស្ថិរភាពហិរញ្ញវត្ថុឱ្យបានរឹងមាំ និងបង្ការចៀសផុតពីបញ្ហាបំណុលវ័ណ្ឌករបស់ប្រជាពលរដ្ឋ។

### ហត្ថលេខារបស់អភិបាល ធនាគារ ហត្ថា ម.ក

កាលបរិច្ឆេទ៖ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១
បានអាន និងឯកភាព



លោក ឡូញ ហៃ
អភិបាលឯករាជ្យ

កាលបរិច្ឆេទ៖ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១
បានអាន និងឯកភាព



លោកបណ្ឌិត ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ

Hattha Bank

Subsidiary of krungsri bank

A member of MUFG, a global financial group